# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 253

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ពង្រឹងគុណភាពឱសថ ឧបករណ៍ បរិក្ខារ ពេទ្យ គ្រឿង សម្អាង និង សុវត្ថិភាព ចំណីអាហារ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |
| ៣. ចំណាយគម្រោងសរុប | $2,220,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងសុខាភិបាល |
| RESPONSIBLE UNIT | Department of Drugs and Food |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | បញ្ចូលក្នុងថវិការ និងឥណទានផ្សេងៗ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ធានាការផ្តល់ឱសថមានគុណភាពក៏តែខ្ពស់
- ពង្រឹងនូវអនាម័យ និងសុវត្ថិភាពចំណីអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយ(ភោជនីយដ្ឋាន អាហារដ្ឋាន ស្តង់លក់ចំណីអាហារ អាហារលក់តាមដងផ្លូវ ។ល។) អាជីវកម្មចំណីអាហារ និងពង្រឹងការអនុវត្តនូវកូនសោគន្លឹះទាំងប្រាំ ដើម្បីបង្កើនសុវត្ថិភាពផ្សារម្ហូបអាហារប្រពៃណី។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

សុខាភិបាល

Health

Health

Health

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

- ពង្រឹងគុណភាពឱសថ
- ពង្រឹងគុណភាពឧបករណ៍ បរិក្ខារ ពេទ្យ។
- ពង្រឹងអនាម័យ និងសុវត្ថិភាពចំណីអាហារនៅក្នុងកន្លែងប្រើប្រាស់ចុងក្រោយ អាជីវកម្មចំណីអាហារ និងពង្រឹងការអនុវត្តនូវកូនសោគន្លឹះទាំងប្រាំ ដើម្បីបង្កើនសុវត្ថិភាពផ្សារម្ហូបអាហារប្រពៃណី។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះមានគោលបំណងសំខាន់គឺ:

-ធានានូវឱសថដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសម្រាប់បំរើសុខភាពទាំងឯកជន និងរដ្ឋក៏ដូចជាការនាំចេញ ។

-ពង្រឹងការតាមដាន និងរាយការណ៍ពីប្រតិកម្មរំខានរបស់ឱសថដែលកើតមានពីការប្រើប្រាស់ឱសថ។ ដើម្បីធានានូវការប្រើប្រាស់ឱសថប្រកបដោយសុវត្ថិភាព។

-ធានាការផ្គត់ផ្គង់ឱសថសារវន្តដល់គ្រប់សេវាសុខាភិបាលសាធារណៈឱ្យមានឱសថប្រើប្រាស់គ្រប់គ្រាន់ ដើម្បីព្យាបាលប្រជាជននិងបង្កើនការទទួលបាននូវការប្រើប្រាស់ឱសថសារវន្តប្រកបដោយសុវត្ថិភាព និងគុណភាពចំពោះប្រជាជនទូទាំងប្រទេស និងធានាការចែកចាយឱសថនៅតាមសេវាសុខាភិបាលឯកជនប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធិភាព។

-ពង្រឹងប្រព័ន្ធ Pharmacovigilance នៅក្នុងប្រទេសកម្ពុជា។

-ស្រាវជ្រាវរកឱសថក្លែងក្លាយ ឱសថអន់គុណភាព ដើម្បីលុបបំបាត់ឱ្យនៅក៏រិតទាបបំផុតតាមដែលអាចធ្វើទៅបាននៅតាមសេវាសុខាភិបាលឯកជន។

-តាមដាន និងស្រាវជ្រាវកន្លែងលក់ឱសថគ្មានច្បាប់អនុញ្ញាត និងសេវាសុខាភិបាលខុសច្បាប់ដែលកើតថ្មី និងចាត់វិធានការលុបបំបាត់ជាបន្ទាន់ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

-ពង្រឹងប្រព័ន្ធចុះបញ្ជិកាឱសថសម័យ ឱសថបុរាណ សម្ភារ បរិក្ខារពេទ្យ និងគ្រឿងសម្អាងស្របតាមបទដ្ឋានរបស់អាស៊ានឱ្យបាន១០០%នូវឱសថដែលចរាចរណ៍ក្នុងប្រទេសកម្ពុជា។

-ពង្រឹងការអនុវត្តន៍គោលការណ៍អនុវត្តល្អក្នុងការចែកចាយផលិតផលឱសថ។

-ពង្រឹងគោលការណ៍អនុវត្តល្អក្នុងឱសថស្ថាន។

-ធានាក្នុងការគ្រប់គ្រងគ្រឹះស្ថានអាហរ៍ណ នីហរ៍ណឱសថ គ្រឿងសម្អាង និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស។

-ធានារាល់ការនាំចូល នាំចេញនូវផលិតផលឱសថមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព។

-បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងឱសថ និងផលិតផលសុខាភិបាល នៅមន្ទីរពេទ្យ ស្រុកប្រតិបត្តិ មណ្ឌលសុខភាពតាមបណ្តាខេត្ត។

-ចុះត្រួតពិនិត្យការគ្រប់គ្រងឱសថញៀន និងឱសថមានឥទ្ធិពលសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្តនៅតាមឱសថស្ថាន ឱសថស្ថានរងនៅតាមបណ្តារាជធានី ខេត្ត។

-បណ្តុះបណ្តាលស្តីពីការគ្រប់គ្រង ចែកចាយ ការប្រើប្រាស់ឱសថញៀន និងឱសថមានឥទ្ធិពលសរសៃប្រសាទ ឬឱសថ

ព្យាបាលជំងឺផ្លូវចិត្តនៅតាមឱសថស្ថាន ឱសថស្ថានរងនៅតាមបណ្តារាជធានី ខេត្ត

-រៀបចំគោលនយោបាយស្តីពីចំណីអាហារលក់តាមដងផ្លូវ។

-បន្តរៀបចំចំបទដ្ឋានគតិយុត្តដែលទាក់ទងនឹងអនាម័យ សុវត្ថិភាពចំណីអាហារ។

-ជំរុញការបណ្តុះបណ្តាលដល់មន្រ្តីភ្នាក់ងារត្រួតពិនិត្យចំណីអាហារនៅតាមរាជធានី ខេត្តទាំង២៥ អំពីនីតិវិធីក្នុងការត្រួតពិនិត្យ វាយតម្លៃ និងតាមដានអនាម័យ សុវត្ថិភាពចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន អាជីវកម្មចំណីអាហារ និងចំណីអាហារលក់តាមដងផ្លូវ។

-បន្តបណ្តុះបណ្តាលការអនុវត្តអនាម័យល្អដល់ម្ចាស់ អ្នកគ្រប់គ្រង ចុងភៅ និងអ្នកបម្រើសេវាចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន អាជីវកម្មចំណីអាហារ និងអ្នកលក់ចំណីអាហារតាមដងផ្លូវ។

-ពង្រឹងការចុះត្រួតពិនិត្យ វាយតម្លៃ និងតាមដានអនាម័យ សុវត្ថិភាពចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន អាជីវកម្មចំណីអាហារផ្សេងៗ និងចំណីអាហារដែលដាក់លក់នៅតាមដងផ្លូវនៅរាជធានីភ្នំពេញ និងបណ្តាខេត្តសម្រាប់ការផ្តល់ មិនផ្តល់និងបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់អនាម័យ និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អប្រភេទA, B និងC។

-រៀបចំការចុះអង្កេត តាមដានអនាម័យ សុវត្ថិភាពចំណីអាហារ( Food hygiene safety surveillance ) ចំពោះចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន អាជីវកម្មចំណីអាហារផ្សេងៗ និងចំណីអាហារលក់តាមដងផ្លូវ ដោយប្រើនូវប្រតិករវិភាគបឋម( Test Kit )ក្នុងការវិភាគរកមេរោគ និងសារធាតុគីមីដែលមាន និងប្រើប្រាស់ក្នុងចំណីអាហារ ធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពអ្នកបរិភោគ។

-រៀបចំប្រព័ន្ធការងារ Food Safety Emergency Response និងការអង្កេតតាមដានស្រាវជ្រាវពីការពុលចំណីអាហារ

-ពង្រឹងការផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យលេខ១៣៣ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារដល់មន្រ្តីសុខាភិបាល ម្ចាស់ផ្សារទំនើប អាជីវករលក់ផលិតផលទឹកដោះគោម្សៅនៅតាមហាងលក់ផលិតផលទឹកដោះគោ។

-ពង្រឹងការចុះត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍អនុក្រឹត្យលេខ១៣៣ នៅតាមទីតាំងលក់ផលិតផលក្នុងព្រះរាជាណាចក្រកម្ពុជា។

-ពង្រឹងការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារសម្រាប់ផលិតផលចំណីអាហារនាំចេញ និងក្នុងស្រុក។

-ពង្រឹងការត្រួតពិនិត្យអនាម័យ សុវត្ថិភាពចំណីអាហារលក់តាមដងផ្លូវ និងពង្រឹងការអនុវត្តនូវកូនសោគន្លឹះទាំងប្រាំដើម្បីបង្កើនសុវត្ថិភាពផ្សារម្ហូបអាហារប្រពៃណី។

-បណ្តុះបណ្តាលស្តីពីអនាម័យ និងសុវត្ថិភាពចំណីអាហារសម្រាប់ផ្សារម្ហូបអាហារប្រពៃណីដល់អ្នកលក់ និងភ្នាក់ងារត្រួតពិនិត្យចំណីអាហារនៅខេត្តកំពត និងខេត្តសៀមរាប។

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

ប្រជាជនទូទៅ និងអ្នកជំងឺក្រីក្រ

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ ? | មិនទានចាប់ផ្តើម |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គំរោងអាចអនុវត្តបានដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**គំរោងត្រូវបាននិងកំពុងអនុវត្តយោងតាមផែនការដែលបានរៀបចំឡើង។បញ្ហាប្រឈមក្នុងការអនុវត្តគំរោងរួមមានកង្វះថវិកា និងធនធានមនុស្សមិនគ្រប់គ្រាន់សម្រាប់អនុវត្ត។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

123456789

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 368.1 | 0.0 | 368.1 | 368.1 | 442.9 | 0.0 | 811.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 368.1 | 0.0 | 368.1 | 368.1 | 442.9 | 0.0 | 811.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 474.8 | 0.0 | 474.8 | 474.8 | 0.0 | 0.0 | 474.8 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារ: | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 474.8 | 0.0 | 474.8 | 474.8 | 0.0 | 0.0 | 474.8 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 842.9 | 0.0 | 842.9 | 842.9 | 442.9 | 0.0 | 1,285.8 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 442.9 | 0.0 | 442.9 | 737.9 | 737.9 | 737.9 | 2,213.7 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 442.9 | 0.0 | 442.9 | 737.9 | 737.9 | 737.9 | 2,213.7 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 400.0 | 0.0 | 400.0 | 2.1 | 2.1 | 2.1 | 6.3 | |
| | | | | | | | | |
| Global Fund | 400.0 | 0.0 | 400.0 | 2.1 | 2.1 | 2.1 | 6.3 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 842.9 | 0.0 | 842.9 | 740.0 | 740.0 | 740.0 | 2,220.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 102.9 | -297.1 | -740.0 | -934.2 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: